ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

# សេចក្តីជូនដំណឹងស្តីពី
# ការប្រកួតប្រជែងរចនានិមិត្តសញ្ញាអេកម៉ិក

សូមជូនដំណឹងដល់សាធារណជនជ្រាបថា ដើម្បីលើកកម្ពស់ការយល់ដឹង និងជំរុញឱ្យស្គាល់កាន់តែច្បាស់អំពីក្របខណ្ឌ យុទ្ធសាស្ត្រនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចអាយ៉េយ៉ាវ៉ាឌី-ចៅប្រាយ៉ា-មេគង្គ ឬហៅកាត់ថា(អេកម៉ិក) (The Ayeyawady - Chao Phraya - Mekong Economic Cooperation Strategy - ACMECS) លេខាធិការដ្ឋានបណ្តោះអាសន្នអេកម៉ិក (ACMECS Interim Secretariat) បានធ្វើការប្រកាសដល់បេក្ខជនពីបណ្តាប្រទេសសមាជិកអេកម៉ិករួមមាន កម្ពុជា ឡាវ មីយ៉ាន់ម៉ា ថៃ និងវៀតណាម ដែលមានអាយុចាប់ពី១៥ឆ្នាំឡើង អាចចូលរួមក្នុងការប្រកួតប្រជែងរចនានិមិត្តសញ្ញាអេកម៉ិក (ACMECS Logo Design Competition)។ និមិត្តសញ្ញាដែលទទួលបានជ័យលាភី នឹងត្រូវយកទៅប្រើប្រាស់លើរាល់ឯកសារ និងការងារពាក់ព័ន្ធក្នុងក្របខណ្ឌអេកម៉ិក។

ការរចនានិមិត្តសញ្ញានេះត្រូវផ្អែកតាមទស្សនាទាន និងបំពេញតាមលក្ខខណ្ឌការប្រកួតប្រជែងដូចមានក្នុងឧបសម្ព័ន្ធទី១ (Annex 1)។

បេក្ខជនជ័យលាភីលេខ១ នឹងទទួលបានប្រាក់រង្វាន់ចំនួន ១,០០០ ដុល្លារអាមេរិក ហើយបេក្ខជនលេខ២ ទទួលបានប្រាក់រង្វាន់លើកទឹកចំនួន ៥០០ ដុល្លារអាមេរិក និងបេក្ខជនលេខ៣ ទទួលបានប្រាក់រង្វាន់លើកទឹកចំនួន ៣០០ ដុល្លារអាមេរិក។

បេក្ខជនដែលមានបំណងចូលរួមប្រកួតប្រជែង ត្រូវបំពេញពាក្យស្នើសុំ **ជាភាសាអង់គ្លេស** ដូចមានក្នុងឧបសម្ព័ន្ធទី២ (Annex 2) ជូនភ្ជាប់ រួចផ្ញើទៅកាន់លេខាធិការដ្ឋានបណ្តោះអាសន្នអេកម៉ិក តាមអាសយដ្ឋានអ៊ីម៉ែល acmecs.sec@gmail.com **ចាប់ពីថ្ងៃផ្សាយដំណឹងនេះតទៅរហូតដល់ថ្ងៃទី ៣១ ខែមីនា ឆ្នាំ២០២៤** ដើម្បីគណៈកម្មាធិការធ្វើការវាយតម្លៃ។

ថ្ងៃព្រហស្បតិ៍ ១៤រោច ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ៨ ខែកុម្ភៈ ឆ្នាំ២០២៤

ACMECS Member Countries and the ACMECS Interim Secretariat

**Calling all CREATIVE and PASSIONATE citizens to enter...**

# ACMECS

**Ayeyawady - Chao Phraya - Mekong Economic Cooperation Strategy**

# LOGO DESIGN COMPETITION



**WINNER!**
**$1,000**
**cash**

**1st Runner Up**
**$500**
**cash**

**2nd Runner Up**
**$300**
**cash**

**Submission Deadline** **31 March 2024**

## WHO CAN APPLY?

Citizens from
**ACMECS Member Countries***
from the age of **15 and above**

All entries must be submitted at
**acmecs.sec@gmail.com**

**For more details about ACMECS and Terms & Conditions**

**Connect with us !**

**Mekong Cooperation Unit**

*Cambodia, Lao PDR, Myanmar, Thailand, Viet Nam / This competition is conducted in English

# ACMECS Logo Design Competition

***************

## 1. Background

The Ayeyawady - Chao Phraya - Mekong Economic Cooperation Strategy (ACMECS) is a sub-regional framework established in 2003, consisting of five Member Countries; namely, Cambodia, Lao PDR, Myanmar, Thailand and Viet Nam with the objective to promote sustainable development and economic growth along the borders, facilitate trade, and narrow the development gaps among the member countries in the Mekong sub-region as well as support ASEAN integration.

Among the myriads of Mekong cooperation frameworks, ACMECS is the only Mekong sub-regional cooperation framework driven by the Mekong countries and serves as a "connector" of sub-regional and regional cooperation frameworks.

At present, the ACMECS Master Plan (2019 – 2023) and its three pillars of cooperation; (1) Seamless Connectivity, (2) Synchronized ACMECS, and (3) Smart and Sustainable ACMECS, remain relevant. Yet, the framework must continue to be ready to adapt to the developmental needs and challenges of the ever-changing geo-political contexts of the Mekong sub-region and the world.

On the occasion of the 20$^{th}$ anniversary of the establishment of ACMECS in 2023, the ACMECS Interim Secretariat organise the ACMECS Logo Design Competition and invites participants from ACMECS member countries for designing an official logo of ACMECS. The logo should portray ACMECS as a forward-looking sub-regional framework contributing to the prosperity, sustainability and well-being of the Mekong people.

## 2. Objectives

To raise awareness of ACMECS framework to the general public of the Mekong countries.

## 3. Expected Output

To launch an official ACMECS logo

**4. Target participants**

Contestants from ACMECS Member Countries with the age of 15 or above.

**5. Theme for logo design**

ACMECS as an adaptive and forward-looking sub-regional cooperation framework and connector with other sub-regional and regional frameworks towards a prosperous and sustainable Mekong sub-region.

**6. Tentative Timetable**

| | **Programme** | **Dates** |
|---|---|---|
| 1 | Public Relations and Official Announcement of ACMECS Logo Design Competition | Social media announcement – 1 February 2024<br><br>Official announcement - Early February 2024* (possibly on the same date as the signing of the MOU) |
| 2 | Entry of ACMECS Logo Design Competition | 1 February – 31 March 2024 |
| 3 | Committee Selection | Within 30 April 2024 |
| 4 | Announcement of results | 3 May 2024 |

**7. Prize**

| | **Programme** | **Reward** |
|---|---|---|
| 1 | 1st Place | 1,000 USD |
| 2 | 1st Runner up | 500 USD |
| 3 | 2nd Runner up | 300 USD |

**8. Relevant Documents** (attached as Annex 1 and 2)

8.1 Terms and Conditions for the ACMECS Logo Design Competition
8.2 Application Form for the ACMECS Logo Design Competition

Annex 1

**Terms and Conditions**
**for**
**ACMECS Logo Design Competition**

***************

- All entries must be submitted through the ACMECS Interim Secretariat's email address at acmecs.sec@gmail.com. Entries could either be an individual or team submission.
- Eligibility for the logo competition are citizens of ACMECS Member countries with the age of 15 or above.
- By submitting an entry, the participants agree to the Terms and Conditions stated in this document.
- Entries must be accompanied by a completed application form in English Language, which include a brief explanation of the idea of the design (200 – 300 words).
- The winning designs of the logo competition shall be the intellectual property of the ACMECS Interim Secretariat. The winners cannot exercise any right over it, after acceptance of the prize. The ACMECS Interim Secretariat shall have the right to modify or edit the winning design of the logo. Relevant agencies of ACMECS Member Countries and the ACMECS Interim Secretariat shall have the right to use the prize-winning logo for promotional and display purposes of ACMECS as well as any other usage and in any form it may deem appropriate.
- The logo must not contain any provocative, objectionable or inappropriate content.
- The logo must be an original design. The Ministry of Foreign Affairs of the Kingdom of Thailand and the ACMECS Interim Secretariat do not bear any responsibility for copyright violations or infringements of intellectual property carried out by the participants. The design of the logo/motto must not infringe on the Intellectual Property Rights of any third party.
- The participant must be the same person who has designed the logo. The Ministry of Foreign Affairs of Thailand follows a zero-tolerance policy towards plagiarism.
- The Ministry of Foreign Affairs of Thailand reserves the right to cancel or amend all or any part of the Contest and/ or the Terms & Conditions/ Technical Parameters/ Evaluation Criteria. However, any changes to the Terms & Conditions/ Technical Parameters/ Evaluation Criteria, or cancellation of the Contest, will be updated/ posted on the Mekong Cooperation Unit Facebook Page. It would be the responsibility of the participants to follow on the changes in the Terms & Conditions/ Technical Parameters/ Evaluation Criteria stated for this competition.
- The responsibility to comply with the guidelines and other conditions fully lies with the participant. The Ministry of Foreign Affairs of Thailand shall not be liable for any dispute raised by a third party.

- The Ministry of Foreign Affairs of Thailand reserves the right to reject any application at any stage prior to selecting the winner.
- It may also be noted herewith that the entries submitted by one individual shall not be viewable to the other participants.

**Technical Parameters**

- Participants should upload the logo in JPEG or PNG or PDF file format.
- A specification sheet containing graphical construction of the design in exact proportions in a bigger size, along with the final design, theme synopsis and concept is required to be submitted by the winner of the competition.
- The logo should be in high resolution with minimum size of 300 DPI.
- The logo should be designed on a digital platform.
- The winner of the competition shall be required to submit the design in an editable and open file format.
- The logo should be usable on the website/social media such as Twitter/Facebook/Instagram and on printed material such as black and white press releases, stationery and signage.
- Participants must not imprint or watermark logo design.
- Logo should be designed in color, and should have graphic elements that allow it to be used with or without the text “ACMECS” or any other relevant wordings.

**Evaluation Criteria**

- All the entries received by the ACMECS Interim Secretariat would be considered by a Selection Committee, comprising representatives from ACMECS Member Countries, for final evaluation.
- Entries would be judged on the basis of elements of creativity, originality, composition, technical excellence, simplicity, artistic merit, visual impact and its relevance to the theme of the logo design.
- The decision of the Selection Committee would be final and binding on all the contestants and no clarifications would be issued to any participants for any of their decisions.
- Disqualified entries shall not be used by the ACMECS Interim Secretariat for any purposes. Shall have no intellectual rights over them. Any legal proceedings arising out of the competition/ its entries/ winners shall be subject to local jurisdiction of Thailand.

**Prize**

- The selected winning entry will be awarded a prize.

Annex 2

**Application Form**
**for the ACMECS Logo Design Competition**

***************

| | |
|---|---|
| 1. Title (Mr. Ms. Mrs. etc.) | |
| 2. First Name | |
| 3. Last Name | |
| 4. Date of Birth | |
| 5. Gender<br>6. (Male, Female or preferred not to say) | |
| 7. Country of Citizenship<br>8. (Only ACMECS Member Countries: Cambodia, Lao PDR, Myanmar, Thailand or Viet Nam) | |
| 9. Occupation | |
| 10. Home Address | |
| 11. Email Address | |
| 12. Phone number | |
| 13. WhatsApp Number | |

| 14. Photocopy of Passport or National ID<br>(Insert a JPG, JPEG or PNG file format within the box below) |
|---|
| |

| 15.Image of Logo<br>(Insert a JPEG or PNG file format within the box below) |
|---|
| |

| 16. Please give a brief explanation on the idea of the design of the ACMECS logo (200 - 300 words). |
|---|
| |

*It is the participant's responsibility to ensure that all the information provided in the application form is correct and complete.*

* * * * * *

ACMECS Interim Secretariat
January 2024

# ការប្រកួតប្រជែងរចនានិមិត្តសញ្ញាអេកម៉ិក

***************

## ១. សាវតា

**យុទ្ធសាស្ត្រនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចអាយេយ៉ាវ៉ាឌី-ចៅប្រាយ៉ា-មេគង្គ** ឬហៅកាត់ថា (អេកម៉ិក) គឺជាក្របខណ្ឌអនុតំបន់ដែលត្រូវបានបង្កើតឡើងនៅឆ្នាំ២០០៣ ដោយមានប្រទេសសមាជិកចំនួន៥ រួមមាន កម្ពុជា ឡាវ មីយ៉ាន់ម៉ា ថៃ និងវៀតណាម ក្នុងគោលបំណងដើម្បីលើកកម្ពស់ការអភិវឌ្ឍប្រកបដោយចីរភាព និងកំណើនសេដ្ឋកិច្ចតាមបណ្តោយព្រំដែន ការសម្រួលពាណិជ្ជកម្ម និងបង្រួមគម្លាតនៃការអភិវឌ្ឍក្នុងចំណោមប្រទេសជាសមាជិកនៅក្នុងអនុតំបន់មេគង្គ ក៏ដូចជាគាំទ្រដល់ការធ្វើសមាហរណកម្មរបស់អាស៊ាន។

ក្នុងចំណោមក្របខណ្ឌនៃកិច្ចសហប្រតិបត្តិការមេគង្គជាច្រើន អេកម៉ិកគឺជាក្របខណ្ឌកិច្ចសហប្រតិបត្តិការតែមួយក្នុងអនុតំបន់មេគង្គដែលផ្តួចផ្តើមឡើងដោយប្រទេសមេគង្គ និងដើរតួនាទីជា «តំណភ្ជាប់» ជាមួយនឹងក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការអនុតំបន់ និងតំបន់ទាំងអស់។

ផែនការមេអេកម៉ិកឆ្នាំ (២០១៩-២០២៣) ដែលមានសសរស្តម្ភ៣ រួមមាន (១) ការតភ្ជាប់ដោយរលូន (២) សេដ្ឋកិច្ចអេកម៉ិកដែលមានភាពស៊ីសង្វាក់ និង (៣) អេកម៉ិកដែលមានភាពឆ្លាតវៃ និងចីរភាព នៅតែមានភាពពាក់ព័ន្ធ ក្នុងពេលបច្ចុប្បន្ន។ យ៉ាងណាក្តី យន្តការអេកម៉ិកត្រូវតែបន្តត្រៀមឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍ និងបញ្ហាប្រឈមនានាដែលបណ្តាលមកពីដំណើរវិវត្តនៃបរិបទភូមិសាស្ត្រនយោបាយក្នុងអនុតំបន់មេគង្គ និងសកលលោក។

ក្នុងឱកាសគម្រប់ខួប២០ឆ្នាំនៃការបង្កើតយន្តការអេកម៉ិកនៅក្នុងឆ្នាំ២០២៣ លេខាធិការដ្ឋានបណ្តោះអាសន្នអេកម៉ិក បានរៀបចំការប្រកួតប្រជែងរចនានិមិត្តសញ្ញាអេកម៉ិក និងអញ្ជើញបេក្ខជនចូលរួមពីបណ្តាប្រទេសសមាជិកអេកម៉ិក ដើម្បីចូលរួមរចនានិមិត្តសញ្ញាផ្លូវការរបស់អេកម៉ិក។ ការរចនានិមិត្តសញ្ញាត្រូវឆ្លុះបញ្ចាំងថា អេកម៉ិកគឺជាក្របខណ្ឌអនុតំបន់ដែលមានចក្ខុវិស័យសម្លឹងឆ្ពោះទៅមុខក្នុងការរួមចំណែកសម្រេចបាននូវវិបុលភាព និរន្តរភាព និងសុខុមាលភាពសម្រាប់ប្រជាជនក្នុងតំបន់មេគង្គ។

## ២. គោលបំណង

ដើម្បីលើកកម្ពស់ការយល់ដឹង និងជំរុញឱ្យស្គាល់កាន់តែច្បាស់ អំពីក្របខណ្ឌអេកម៉ិកដល់សាធារណជននៅក្នុងអនុតំបន់មេគង្គ។

## ៣. លទ្ធផលរំពឹងទុក

ដើម្បីដាក់ដំណើរការនូវនិមិត្តសញ្ញាផ្លូវការរបស់អេកមិុក។

## ៤. លក្ខណៈសម្បត្តិរបស់បេក្ខជនចូលរួមប្រកួត

បេក្ខជនមកពីបណ្តាប្រទេសសមាជិកអេកមិុកដែលមានអាយុចាប់ពី១៥ឆ្នាំឡើងទៅ។

## ៥. មូលបទនៃការរចនានិមិត្តសញ្ញា

អេកមិុកជាក្របខណ្ឌកិច្ចសហប្រតិបត្តិការអនុតំបន់ ដែលអាចសម្របខ្លួន និងមានចក្ខុវិស័យសម្លឹងឆ្ពោះទៅមុខ ហើយជាតំណភ្ជាប់នៃក្របខណ្ឌកិច្ចសហប្រតិបត្តិការអនុតំបន់ និងតំបន់ដ៏ទៃទៀត សំដៅឆ្ពោះទៅរកវិបុលភាព និងនិរន្តរភាពក្នុងអនុតំបន់មេគង្គ។

## ៦. ដំណាក់កាលនៃការជ្រើសរើស

| | ដំណាក់កាល | កាលបរិច្ឆេទ |
|---|---|---|
| ១ | ទំនាក់ទំនងសាធារណៈ និងការផ្សព្វផ្សាយជាផ្លូវការនៃការប្រកួតប្រជែងរចនានិមិត្តសញ្ញាអេកមិុក | ការផ្សព្វផ្សាយជាផ្លូវការ<br>- ដើមខែកុម្ភៈ ឆ្នាំ២០២៤* |
| ២ | ការបើកឱ្យចូលរួមប្រកួតប្រជែងរចនានិមិត្តសញ្ញាអេកមិុក | ចាប់ពីថ្ងៃទី០១ ខែកុម្ភៈ ដល់ ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៤ |
| ៣ | ការជ្រើសរបស់គណៈកម្មការ | ក្នុងអំឡុងថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៤ |
| ៤ | ការប្រកាសលទ្ធផល | ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២៤ |

## ៧. ប្រាក់រង្វាន់

| | ជ័យលាភី | រង្វាន់ |
|---|---|---|
| 1 | លេខ ១ | ១០០០ ដុល្លារអាមេរិក |
| 2 | លេខ ២ | ៥០០ ដុល្លារអាមេរិក |
| 3 | លេខ ៣ | ៣០០ ដុល្លារអាមេរិក |

## ៨. ឯកសារពាក់ព័ន្ធ (សូមមើលក្នុងឧបសម្ព័ន្ធទី១ និងទី២)

៨.១ លក្ខខណ្ឌនៃការចូលរួមការប្រកួតប្រជែងរចនានិមិត្តសញ្ញាអេកមិុក

៨.២ ទម្រង់ពាក្យស្នើសុំចូលរួមការប្រកួតប្រជែងរចនានិមិត្តសញ្ញាអេកមិុក

**<u>ឧបសម្ព័ន្ធទី១</u>**

**លក្ខខណ្ឌ**
**សម្រាប់ចូលរួមការប្រកួតប្រជែងរចនានិមិត្តសញ្ញាអេកមិក**

***************

- បេក្ខជនទាំងអស់ ត្រូវដាក់ពាក្យស្នើសុំចូលរួមប្រកួតប្រជែងមកកាន់លេខាធិការដ្ឋានបណ្ដោះអាសន្នអេកមិក តាមអាស័យដ្ឋានអ៊ីម៉ែល acmecs.sec@gmail.com ។ បេក្ខជនអាចចូលរួមការប្រកួតប្រជែងជាបុគ្គល ឬជាក្រុម។
- បេក្ខជនដែលមកពីបណ្ដាប្រទេសសមាជិកអេកមិក មានអាយុចាប់ពី១៥ឆ្នាំឡើងទៅ អាចមានសិទ្ធិចូលរួមការប្រកួតប្រជែងបាន។
- បេក្ខជនត្រូវយល់ព្រមទៅនឹងលក្ខខណ្ឌដែលបានចែងក្នុងឧបសម្ព័ន្ធនេះ ដើម្បីមានសិទ្ធិចូលរួមការប្រកួតប្រជែង។
- បេក្ខជនចូលរួមការប្រកួតប្រជែង ត្រូវបំពេញពាក្យស្នើសុំ **<u>ជាភាសាអង់គ្លេស</u>** អមជាមួយខ្លឹមសារពន្យល់អត្ថន័យនៃការរចនានិមិត្តសញ្ញាដោយសង្ខេប (ចន្លោះពី ២០០ ទៅ ៣០០ ពាក្យ)។
- និមិត្តសញ្ញាដែលទទួលបានជ័យលាភី នឹងក្លាយជាកម្មសិទ្ធិរបស់លេខាធិការដ្ឋានបណ្ដោះអាសន្នអេកមិក។ បេក្ខជនជ័យលាភី ពុំមានកម្មសិទ្ធិទៅលើនិមិត្តសញ្ញាឡើយ បន្ទាប់ពីទទួលបាននូវប្រាក់រង្វាន់ជ័យលាភី។ លេខាធិការដ្ឋានបណ្ដោះអាសន្នអេកមិក មានសិទ្ធិកែប្រែលើនិមិត្តសញ្ញាជ័យលាភី តាមការចាំបាច់។ ក្រសួង/ស្ថាប័នពាក់ព័ន្ធនៃបណ្ដាប្រទេសសមាជិកអេកមិក និងលេខាធិការដ្ឋានបណ្ដោះអាសន្នអេកមិកមានសិទ្ធិប្រើប្រាស់និមិត្តសញ្ញាជ័យលាភី ក្នុងគោលបំណងផ្សព្វផ្សាយការងារដែលពាក់ព័ន្ធនឹងយន្តការអេកមិក ក៏ដូចជាការប្រើប្រាស់ផ្សេងៗ ឬក្នុងទម្រង់ណាមួយដែលសមស្រប។
- និមិត្តសញ្ញា មិនត្រូវមានមាតិកាដែលពាក់ព័ន្ធនឹងបញ្ហារសើប ឬមាតិកាមិនសមរម្យណាមួយឡើយ។
- និមិត្តសញ្ញាត្រូវមានភាពជាលំនាំដើម។ ក្រសួងការបរទេសថៃ និងលេខាធិការដ្ឋានបណ្ដោះអាសន្នអេកមិក មិនទទួលខុសត្រូវរាល់បញ្ហារំលោភបំពានលើសិទ្ធិអ្នកនិពន្ធ ឬកម្មសិទ្ធិបញ្ញា ដែលបង្កឡើងដោយបេក្ខជនចូលរួមរចនានិមិត្តសញ្ញាឡើយ។ ការរចនានិមិត្តសញ្ញាមិនត្រូវអនុញ្ញាតិឱ្យមានការរំលោភបំពានលើកម្មសិទ្ធិបញ្ញានៃភាគីទីបីណាមួយឡើយ។
- បេក្ខជនចូលរួមការប្រកួត ត្រូវតែជាអ្នករចនានិមិត្តសញ្ញាដោយផ្ទាល់។ ក្រសួងការបរទេសថៃ នឹងមិនមានការលើកលែងចំពោះការលួចចម្លងនិមិត្តសញ្ញាពីភាគីណាមួយឡើយ។
- ក្រសួងការបរទេសថៃ សូមរក្សាសិទ្ធិចំពោះការលុបចោល ឬកែប្រែលើលក្ខខណ្ឌណាមួយពាក់ព័ន្ធនឹងការប្រកួតប្រជែង ឬលក្ខខណ្ឌនៃការចូលរួម កត្តាបច្ចេកទេស និងការវាយតម្លៃផ្សេងៗ។ ទោះយ៉ាងណាក៏ដោយ រាល់ការកែប្រែលើលក្ខខណ្ឌណាមួយនៃការប្រកួត និងការចូលរួម កត្តាបច្ចេកទេស ឬលក្ខខណ្ឌនៃការវាយតម្លៃផ្សេងៗ នឹងត្រូវបានដាក់ផ្សព្វផ្សាយលើគេហទំព័រFacebookផ្លូវការរបស់នាយកដ្ឋានសហប្រតិបត្តិការមេគង្គ

នៃក្រសួងការបរទេសថៃ។ បេក្ខជនត្រូវតាមដាន និងគោរពតាមរាល់ការកែប្រែណាមួយទៅលើលក្ខខណ្ឌនៃការចូលរួម កត្តាបច្ចេកទេស លក្ខខណ្ឌនៃការវាយតម្លៃ ដូចដែលបានចែងនៅក្នុងការប្រកួតនេះ។

- បេក្ខជនត្រូវមានទំនួលខុសត្រូវចំពោះការអនុវត្តតាមសេចក្តីណែនាំ និងលក្ខខណ្ឌផ្សេងៗរបស់ការប្រកួតប្រជែង។ ក្រសួងការបរទេសថៃនឹងមិនទទួលខុសត្រូវលើជម្លោះណាមួយអះអាងឡើងដោយភាគីទីបីឡើយ។
- ក្រសួងការបរទេសថៃ សូមរក្សាសិទ្ធិក្នុងការបដិសេធចំពោះពាក្យស្នើសុំរបស់បេក្ខជនចូលរួម នៅរាល់ដំណាក់កាលមុននឹងឈានទៅដល់ការជ្រើសរើសបេក្ខជនជ័យលាភី។
- និមិត្តសញ្ញារបស់បេក្ខជនចូលរួមប្រកួតជាលក្ខណៈបុគ្គល ត្រូវតែរក្សាការសំងាត់ និងមិនអនុញ្ញាតឱ្យចែកចាយទៅបេក្ខជនដទៃទៀតឡើយ។

**កត្តាបច្ចេកទេស**

- បេក្ខជនចូលរួមការប្រកួតប្រជែងត្រូវផ្ញើនិមិត្តសញ្ញាក្នុងទម្រង់រូបភាព JPEG ឬ PNG ឬទម្រង់ PDF។
- បេក្ខជនចូលរួមការប្រកួតប្រជែងត្រូវផ្ញើគំរូរចនានិមិត្តសញ្ញាជាក្រាហ្វិក មានសមាមាត្រទំហំធំ រួមជាមួយនឹងរូបនិមិត្តសញ្ញាចុងក្រោយ (Final logo design) អមជាមួយនឹងការពន្យល់អត្ថន័យសង្ខេបនៃគំនិតច្នៃប្រឌិតនិមិត្តសញ្ញារបស់ខ្លួន។
- រូបនិមិត្តសញ្ញាត្រូវមានគុណភាពច្បាស់ជាមួយនឹងទំហំអប្បបរមា ៣០០ DPI ។
- រូបនិមិត្តសញ្ញាត្រូវតែរចនាឡើងនៅលើកម្មវិធីឌីជីថល។
- បេក្ខជនជ័យលាភីតម្រូវឱ្យផ្ញើនូវរូបនិមិត្តសញ្ញាក្នុងទម្រង់ដែលអាចកែសម្រួលបាន។
- និមិត្តសញ្ញាត្រូវតែមានទម្រង់សមស្រប សម្រាប់ការប្រើប្រាស់នៅលើមធ្យោបាយផ្សព្វផ្សាយ រួមមានគេហទំព័រ/ប្រព័ន្ធផ្សព្វផ្សាយសង្គមផ្សេងៗដូចជា Twitter/Facebook/Instagram និងនៅលើសម្ភារៈបោះពុម្ពដូចជាសេចក្តីប្រកាសព័ត៌មានពណ៌សខ្មៅ និងសម្ភារៈការិយាល័យ និងផ្លាកសញ្ញាផ្សេងៗ។
- បេក្ខជនមិនអនុញ្ញាតឱ្យដាក់ផ្លាកសញ្ញាបញ្ជាក់ពីកម្មសិទ្ធិដើម (watermark) នៅលើនិមិត្តសញ្ញាដែលដាក់ចូលរួមប្រកួតឡើយ។
- និមិត្តសញ្ញាត្រូវរចនាឡើងជារូបភាពមានពណ៌ និងមានក្រាហ្វិកដែលអនុញ្ញាតឱ្យប្រើប្រាស់បានដោយមាន ឬមិនមានពាក្យ "ACMECS") ឬអាចប្រើប្រាស់បានជាមួយពាក្យដ៏ទៃផ្សេងទៀត។

**លក្ខខណ្ឌវាយតម្លៃ**

- រាល់ពាក្យស្នើសុំចូលរួមប្រកួតប្រជែង ដែលលេខាធិការដ្ឋានបណ្តោះអាសន្នអេកម៉ិកទទួលបាន នឹងត្រូវដាក់បញ្ជូនទៅគណៈកម្មការជ្រើសរើស ដែលក្នុងនោះរួមមានតំណាងមកពីប្រទេសសមាជិកអេកម៉ិកទាំងអស់សម្រាប់ធ្វើការវាយតម្លៃចុងក្រោយ។
- បេក្ខជន នឹងត្រូវធ្វើការវិនិច្ឆ័យលើមូលដ្ឋានលើ គំនិតច្នៃប្រឌិត ភាពជាលំនាំដើម ត្រឹមត្រូវតាមក្បួនខ្នាតបច្ចេកទេសនៃការរចនា ភាពសាមញ្ញ ស្អាតតាមគោលការណ៍សិល្បៈ រូបភាពច្បាស់ និងឆ្លុះបញ្ចាំងទៅនឹងមូលបទនៃការរចនានិមិត្តសញ្ញា។

- ការសម្រេចចិត្តរបស់គណៈកម្មការជ្រើសរើស នឹងចាត់ទុកជាការសម្រេចចុងក្រោយ។ គណៈកម្មការសូមរក្សាសិទ្ធមិនឆ្លើយតប ឬបកស្រាយបញ្ជាក់ពីមូលហេតុណាមួយចំពោះបេក្ខជនចូលរួមប្រកួតលើរាល់ការសម្រេចចិត្តរបស់គណៈកម្មការនោះឡើយ។
- លេខាធិការដ្ឋានបណ្តោះអាសន្នអេកម៉ិកមិនមានកម្មសិទ្ធិបញ្ញាលើនិមិត្តសញ្ញាដែលពុំទទួលបានជ័យលាភី ក៏ដូចជាមិនអាចយកទៅប្រើប្រាស់សម្រាប់គោលបំណងណាមួយឡើយ។ រាល់នីតិវិធីច្បាប់ដែលពាក់ព័ន្ធនឹងការប្រកួតប្រជែង /ការចូលរួម/ បេក្ខជនជ័យលាភី ត្រូវស្ថិតនៅក្រោមយុត្តាធិការរបស់ព្រះរាជាណាចក្រថៃ។

**រង្វាន់**

- និមិត្តសញ្ញាដែលទទួលជ័យលាភីនឹងទទួលបានប្រាក់រង្វាន់។